E20-18

# ការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍



ករណីសិក្សា

នៅឧទ្យានជាតិព្រះសីហនុ " រាម " ក្រុងព្រះសីហនុ

និងដែនជំរកសត្វព្រៃពាមក្រសោប ខេត្តកោះកុង

នៃព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវ និងចងក្រងដោយៈ

លោក ជ័យ ទេពវត្ដា

លោក សោម ជា

លោក ស៊ុយ ធា

លោក ឡេង សំអាត

សំរបសំរួលដោយៈ

អ្នកស្រី សូ ស្រីចុំ

លោក អ៊ុក លី ឃីម

២០០២

ម.ព.ឯ.ក AIDOC

Code: 143-036

Date:

Donated by:

# ការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍

## ករណីសិក្សា

**នៅឧទ្យានជាតិព្រះសីហនុ "រាម " និងដែនជំរកសត្វព្រៃ "ពាមក្រសោប"**

**នៃព្រះរាជាណាចក្រកម្ពុជា**


**ស្រាវជ្រាវ និងចងក្រងដោយ**

លោក ជ័យ ពេជរតនា

លោក សោម ជា

លោក ឡេង សំអាត

**សំរបសំរួលដោយ:**

អ្នកស្រី សូ ស្រីមុំ

លោក អ៊ុក លី ឃីម


**២០០២**

គំរោងគ្រប់គ្រងធនធានតំបន់ឆ្នេរដោយផ្អែកលើសហគមន៍ (CBNRM) ចំនួនពីរ បានធ្វើនៅក្នុងឧទ្យានជាតិរាម (RNP) និងដែនជំរកសត្វព្រៃពាមក្រសោប (PKWS) គឺជាគំរូដំបូង នៃគំរោងគ្រប់គ្រងធនធានតំបន់ឆ្នេរដោយមានការចូលរួម នៅក្នុងប្រទេសកម្ពុជា។ មានអង្គការ និងអ្នកផ្តល់ជំនួយផ្សេងៗដូចជា UNDP, WI, CZM, IDRC បានគាំទ្រគំរោងដែលបានធ្វើនៅក្នុងឧទ្យានជាតិរាម។ ចំពោះគំរោងដែលបានធ្វើនៅក្នុងដែនជំរកសត្វព្រៃ"ពាមក្រសោប" គឺគំរោងការគ្រប់គ្រងធនធានព្រៃកោងកាងដោយមានការចូលរួម ត្រូវបានផ្តល់ថវិកាដោយ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសកាណាដា (IDRC). ដំណើរការនៃការងាររៀបចំសហគមន៍ ដែលនឹងធ្វើការពិភាក្សានៅក្នុងករណីសិក្សានេះ គឺផ្អែកទៅលើសកម្មភាពប្រចាំថ្ងៃរបស់អ្នកភូមិ និងការងារនៃក្រុមគំរោង។ ក្រុមការងារបានប្រមូលពតិមាន និងធ្វើអោយកាន់តែប្រសើរឡើងតាមរយៈកិច្ចប្រជុំផ្សេងៗ ការសំភាសន៍ និងការពិភាក្សាតាមរយៈការអនុវត្តន៍នៃគំរោងនីមួយៗ។

ទោះបីជាគំរោងទាំងពីរនេះ ជាគំរូដំបូងនៃការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយផ្អែកលើសហគមន៍ ដែលការចងក្រងឯកសារ ត្រូវបានគេទទួលស្គាល់ថាជា សមាសភាគដ៏សំខាន់នៃការរួមចំណែក និងការវិភាគសកម្មភាពគំរោងទាំងនេះ និងសំរាប់ការផ្សព្វផ្សាយពតិមាននេះដល់សហគមន៍មូលដ្ឋានផ្សេងៗទៀត និងដល់ស្ថាប័នពាក់ព័ន្ធដែលធ្វើការទាក់ទងទៅ នឹងការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយផ្អែកលើសហគមន៍។ ទាក់ទងទៅនឹងការទទួលស្គាល់នេះគំរោងទាំងពីរបានចាប់អារម្មណ៍ សហប្រតិបត្តិការជាមួយ គំរោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម (គំរោងនេះផ្តល់ថវិកាដោយ IDRC/WWF &OA) ដែលគោលបំណងរបស់គំរោងនេះ ផ្តោតលើការចងក្រងឯកសារស្តីអំពី គំរោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមក្នុងប្រទេសកម្ពុជា។ លើសពីនេះទៀត ការធ្វើការងារជាមួយការសរសេរករណីសិក្សា អំពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមលើកដំបូងបានផ្តល់ឱកាសដល់គំរោងទាំងពីរ និងអ្នកភូមិដែលធ្វើការទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម (CBNRM) ដើម្បីរៀនជំនាញសរសេរបន្ថែមទៀត និងដើម្បីតភ្ជាប់បណ្តាញជាមួយគំរោង និងអ្នកភូមិផ្សេងៗទៀតដែលធ្វើការទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមក្នុងប្រទេសកម្ពុជា។

RECOFTC

IDRC
CRDI
CANADA

Oxfam
America

WWF

**ស្រាវជ្រាវ និងចងក្រងករណីសិក្សាដោយៈ**

**លោក ជ័យ ពេជរតនា**

អនុប្រធានមន្ទីរបរិស្ថាន ខេត្តកោះកុង

**លោក សោម ផា**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកោះកុង

**លោក ឡេង សំអាត**

ការិយាល័យជលផល ក្រុងព្រះសីហនុ

**អ្នកសំរបសំរួលដោយៈ**

**អ្នកស្រី ស្ង ស្រីមុំ**

មន្ត្រីសមភាគីរវាងក្រសួងកសិកម្ម និងគំរោងស្តីពី " ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍"

នៃអង្គការ WWF

**លោក អ៊ុក លីយីម**

មន្ត្រីសមភាគីរវាង ក្រសួងបរិស្ថាន និងគំរោង "ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង"

**ទីប្រឹក្សា**

**លោក ទឹម ណារុង**

**លោក តូ ប៊ីខាស្សិន**

**កញ្ញា ម៉ាលីសា**

**កែសំរួលករណីសិក្សា**

**កញ្ញា ម៉ាលីសា**

**លោក ទិនណិត វៀបី**

**ឧបត្ថម្ភដោយអង្គការៈ**

គំរោង "ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង" (PMMR)

គំរោងស្តីពី " ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍" នៃអង្គការ WWF

គំរោងគ្រប់គ្រងតំបន់ឆ្នេរ (CZM)

មជ្ឈមណ្ឌលស្រាវជ្រាវសំរាប់អភិវឌ្ឍន៍អន្តរជាតិ (IDRC)

អុកស្វាមអាមេរិកាំង

មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់ (RECOFTC)

## អារម្ភកថា
## ដំណើរការសរសេរករណីសិក្សា

ដោយទទួលស្គាល់ថា ការគ្រប់គ្រងធនធានដោយសហគមន៍ (CBNRM) គឺជាទស្សនៈ និងការអនុវត្តន៍ថ្មីមួយចំពោះប្រទេសកម្ពុជា ការចងក្រងឯកសារអំពីបទពិសោធន៍មូលដ្ឋាន និងមេរៀនដែលទទួលនេះ បង្កើតចេញជាសមាសភាគសំខាន់មួយ នៃការវិភាគ និងការចែករំលែកពត៌មានរវាងសហគមន៍មូលដ្ឋាន គំរោង និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ ដែលធ្វើការទាក់ទង CBNRM នេះ ។

ការចងក្រងករណីសិក្សានេះ គឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរៀនសូត្រចម្រុះមួយ (ដោយផ្អែកលើគំរូវដ្តរៀនសូត្រដែលជាបទពិសោធន៍មួយ) ដែលមានរយៈពេលចាប់ពីខែ មិថុនា ឆ្នាំ ២០០១ ដល់ ខែវិច្ឆិកា ឆ្នាំ ២០០២ និងអាចមានរយៈពេលយូរជាងនេះទៅទៀត។ ការបណ្តុះបណ្តាលដំបូងអំពីការសរសេរករណីសិក្សាដែលបានធ្វើឡើង នៅខេត្តសៀមរាបសំរាប់អ្នកអនុវត្តគំរោង CBNRM ជាង ៣០នាក់ នៅខែកក្កដា ឆ្នាំ ២០០១ ដើម្បីផ្តល់ជំនាញគ្រឹះ សំរាប់ការសិក្សាស្រាវជ្រាវ PRA ការវិភាគពត៌មាន ការសរសេរអត្ថបទ និងចងក្រងឯកសារ។ ជាលទ្ធផល នៃតម្រូវការខ្ពស់សំរាប់ការងារប្រភេទនេះ វគ្គបណ្តុះបណ្តាល ករណីសិក្សាមួយបានធ្វើឡើងនៅ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅខេត្តរតនៈគីរី ដែលមានអ្នកចូលរួមជាង ៤០ នាក់ ដើម្បីបង្កើនជំនាញខាងការស្រាវជ្រាវ និងជំនាញសរសេរអត្ថបទ នឹងដើម្បីផ្តួចផ្តើមបង្កើតជាក្របខ័ណ្ឌការងារដែលជាទស្សនទានមួយសំរាប់ការងារ CBNRM នៅក្នុងប្រទេសកម្ពុជា។ ជាលទ្ធផលបានមកពីការបណ្តុះបណ្តាលនេះ យើងបានរៀបចំផែនការការងារករណីសិក្សាមួយដែលមានបញ្ចូលទាំងការកំណត់ប្រធានបទ និងសេចក្តីព្រាងគំនិត ។

ករណីសិក្សានេះ គឺជាផ្នែកមួយនៃករណីសិក្សាចំនួន ១០ ធ្វើការផ្តោតទៅលើទាំងបញ្ហាជលផល និងបញ្ហា ព្រៃឈើដែលបានបង្កើត ឡើងនៅក្នុងភូមិសាស្ត្រសំខាន់ ៤ នៃប្រទេសកម្ពុជាដែលមាន តំបន់ខ្ពង់រាប (ខេត្តរតនៈគីរី និងមណ្ឌលគីរី) តំបន់ទំនាបកណ្តាល (ខេត្តពោធិ៍សាត់ និងកំពង់ឆ្នាំង) តំបន់ទន្លេមេគង្គ ឬទន្លេសាប (ខេត្តស្ទឹងត្រែង និងខេត្តសៀមរាប) និងតំបន់ឆ្នេរ (ខេត្តកោះកុង និងកំពង់សោម)។

តាមករណីជាច្រើនសេចក្តីព្រាងលើកទី១ របស់ករណីសិក្សាទាំង១០ ត្រូវបានបង្កើតឡើងដោយក្រុមស្រាវជ្រាវ និងអ្នកនិពន្ធចម្រុះដោយចាប់ពី ខែមករា ដល់ខែមេសា ឆ្នាំ ២០០២។ សេចក្តីព្រាងលើកទី២ ត្រូវបានលើកយកមកបង្ហាញដើម្បីទទួលយកនូវការផ្តល់យោបល់ក្នុងពេលធ្វើសិក្ខាសាលា និងសិក្ខាសាលាបូកសរុបដែលបានធ្វើនៅខេត្តកោះកុងក្នុង ខែឧសភា ឆ្នាំ២០០២។ នៅពេលនោះករណីសិក្សាទាំងនេះត្រូវបានពិនិត្យមើលបកប្រែជាភាសាអង់គ្លេស ហើយបានធ្វើការកែសម្រួល ដើម្បីបោះពុម្ព និងផ្សព្វផ្សាយ។ អ្នកសំរបសំរួលគំរោងនៅតាមមូលដ្ឋានដើរតួនាទីឈានមុខ ក្នុងការជ្រើសរើសប្រធានបទសម្រាប់ការសិក្សាស្រាវជ្រាវ ការប្រមូលពត៌មាន និងការសរសេរអត្ថបទ។ អ្នកសម្របសម្រួល

និងទីប្រឹក្សាថ្នាក់ជាតិផ្តល់ជាជំនួយលើការពិនិត្យមើលគំរោងករណីសិក្សា ការវិភាគពតិមាន ការបកប្រែ និងការកែសម្រួល ។

ដោយធ្វើការតាមគំនិតផ្តួចផ្តើមនេះ បានផ្តល់ឱ្យអ្នកចូលរួមក្នុងកម្រិតផ្សេងៗគ្នានូវឱកាសរៀនជំនាញបានកាន់តែច្រើន ដើម្បីចែករំលែកបទពិសោធន៍ជាមួយគំរោង និងមនុស្សផ្សេងៗ ដែលធ្វើការខាងការងារ CBNRM នៅទូទាំងប្រទេសកម្ពុជា។ តាមមធ្យោបាយបែបនេះ គំនិតផ្តួចផ្តើមចងក្រងករណីសិក្សា CBNRM ត្រូវបានគេប្រើជាឧបករណ៍មួយសម្រាប់បង្កើតជាបណ្តាញការងារ និងចែករំលែកមេរៀនដែលទទួលបាន។ ករណីសិក្សាទាំងនេះនឹងត្រូវ បានគេចែករំលែកផងដែរនៅតាមវេទិកានានាដូចជា សិក្ខាសាលា CBNRM ដែលនឹងធ្វើនៅខែ វិច្ឆិកា ឆ្នាំ ២០០២។ គេរំពឹងទុកថាលទ្ធផលនេះនឹងត្រូវបានប្រើប្រាស់ដើម្បីជាពតិមានដល់ការបង្កើតគោលនយោបាយទៅថ្ងៃមុខនៅក្នុងប្រទេសកម្ពុជា ។

## មាតិការអត្ថបទ

## ការគ្រប់គ្រងធនធានតំបន់ឆ្នេរមានការចូលរួមពីសំណាក់សហគមន៍នេសាទ បាននាំមកនូវ ការកាត់បន្ថយសកម្មភាពនេសាទខុសច្បាប់ និងការកើនឡើងធនធានក្នុងតំបន់ដែលសហគមន៍ បានចូលរួមការពារ


អារម្ភកថា ........ ៣

១-សេចក្តីផ្តើម: ........ ៧

២- ដំណើរការគ្រប់គ្រងសហគមន៍នេសាទនៅឧទ្យានជាតិព្រះសីហនុ "រាម" និង នៅដែនជំរកសត្វព្រៃពាមក្រសោប ........ ៨

២.១-មូលហេតុដែលនាំឱ្យមានការបង្កើតសហគមន៍នៅតំបន់ទាំងពីរ: ........ ៨

ក-ចំនុចខុសគ្នា ........ ៩

ខ-ចំនុចដូចគ្នា ........ ១០

២-២-ដំណើរការរៀបចំសហគមន៍ ........ ១០

២.២.១-ប្រវត្តិនៃការបង្កើតសហគមន៍នៅតំបន់ទាំងពីរ ........ ១០

២.២.២- ការរៀបចំក្រុម និងគណៈកម្មការសហគមន៍ ........ ១៤

២.២.៣- ការរៀបចំលក្ខន្តិកៈ និង បទបញ្ញត្តិ ........ ១៤

២.៣-ការគ្រប់គ្រងសហគមន៍នេសាទ: ........ ១៥

២.៣.១-រៀបចំផែនការគ្រប់គ្រង ........ ១៥

២.៣.២ ពីការធ្វើផែនការនិងបទបញ្ញាតិសហគមន៍ដែលបានចែងមកការអនុវត្តជាក់ស្តែង ........ ១៦

៣. សន្និដ្ឋាន និងអនុសាសន៍: ........ ២១

តារាងឧបសម្ព័ន ........ ២៣

ឧបសម្ព័នទី១ : ប្រវត្តិគំរោង **PMMR** ........ ២៣

ឧបសម្ព័នទី២ : គំរោង ការគ្រប់គ្រងតំបន់ឆ្នេរដោយសហគមន៍ នៅរាម ក្រុងព្រះសីហនុ ........ ២៥

ឧបសម្ព័នទី៣ : គំរោងករណីសិក្សាការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម ........ ២៧

## ការគ្រប់គ្រងធនធានតំបន់ឆ្នេរមានការចូលរួមពីសំណាក់សហគមន៍នេសាទ បាននាំមកនូវការកាត់បន្ថយសកម្មភាពនេសាទខុសច្បាប់ និងការកើនឡើងធនធានក្នុងតំបន់ដែលសហគមន៍បានចូលរួមការពារ

### ១.សេចក្តីផ្តើម:

ព្រះរាជាណាចក្រកម្ពុជាមានឆ្នេរប្រវែង ៤៣៥ គ.ម លាតសន្ធឹងចាប់ពីប្រទេសថៃដល់ប្រទេសវៀតណាម គ្របដណ្តប់លើខេត្តក្រុងចំនួន៤គឺ ខេត្តកោះកុង ក្រុងព្រះសីហនុ ខេត្តកំពត និងក្រុងកែប ដែលមានប្រជាជនរស់នៅប្រមាណ ៨៤៥.៥០០ នាក់ (MoE ១៩៩៨) ក្នុងចំណោមនោះភាគច្រើនបានពឹងពាក់ទាំងស្រុងទៅលើធនធានជលផល សំរាប់ការរស់នៅប្រចាំថ្ងៃ។ តំបន់ឆ្នេរកម្ពុជាសំបូរទៅដោយធនធានមានជាអាទិ៍ ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម ត្រី គ្រប់ប្រភេទសត្វព្រៃ ប្រជុំកោះ និងឆ្នេរខ្សាច់ជាដើម។ ប៉ុន្តែធនធានទាំងនេះពីមួយឆ្នាំទៅមួយឆ្នាំមានការថយចុះជាលំដាប់ដោយសារកំណើនប្រជាជន ការគ្រប់គ្រងមិនបានល្អ និងការប្រើប្រាស់មានភាពអានាធិបតេយ្យ។ កំឡុងឆ្នាំ ១៩៩៣ ក្រោយពេលកម្ពុជាប្រកាន់យករបបប្រជាធិបតេយ្យ សេរីពហុបក្ស តំបន់ឆ្នេរ ពិសេសខេត្តកោះកុង ត្រូវរងនូវសំពាធនៃ ការហូរចូលប្រជាពលរដ្ឋពីខេត្តក្នុងតំបន់ទំនាបកណ្តាល ដែលសង្ឃឹមថាជីវភាពរបស់ពួកគេនឹងមានភាពល្អប្រសើរអាស្រ័យ ដោយធនធានធម្មជាតិតំបន់ឆ្នេរ (PMMR Rept. 2000)។

ដោយតំរូវការទីផ្សារចេះតែកើនឡើងនិងដោយមានការឃុបឃិតពីសំណាក់អ្នកមានអំណាច និងអ្នកមានប្រដាប់



ព្រៃកោងកាងដែលបានកាប់បំផ្លាញ (ពាមក្រសោប:១៩៩៩)

អាវុធផង ភាពអានាធិបតេយ្យនៃការទាញយកធនធានបានកើនឡើងខ្លាំង ដូចជា ការនេសាទខុសច្បាប់ ការកាប់រានព្រៃកោងកាងធ្វើអាជីវកម្ម ធ្វើធ្យូង ធ្វើជាស្រែបង្គា ស្រែក្តាម ចំការដំណាំ ផ្ទះសំណាក់ លំនៅដ្ឋាន។ល។ ដូចគ្នានេះដែរ រាមនិងពាមក្រសោបដែលជាតំបន់ការពារធម្មជាតិនៅតំបន់ឆ្នេរ ក៏រងនូវការបំផ្លាញយ៉ាងដំណំដែរ ទោះបីជាមានការខិតខំប្រឹងប្រែង ទប់ស្កាត់ពីស្ថានប័នជំនាញបរិស្ថាន និងជលផលក្តី។ ចំណែកឯការគ្រប់គ្រង របស់ស្ថាប័នជំនាញពុំមានប្រសិទ្ធិភាពទេដោយខ្វះខាតលើមធ្យោបាយ សំភារៈ និងថវិកា សំរាប់អនុវត្តការងារ។ បន្ថែមពីនេះទៀត មិនមានកិច្ចសហការល្អរវាងស្ថាប័ននានា និងអាជ្ញាធរមូលដ្ឋាន។ ម្យ៉ាងវិញទៀតមានភាពត្រួតស៊ីគ្នានូវតួនាទីនៃបណ្តាអង្គភាពពាក់ព័ន្ធនានា។ ឯច្បាប់(ក្រិត្យច្បាប់លេខ៣៣) ហួសសម័យសំរាប់អនុវត្តនាពេលបច្ចុប្បន្ន។

ប្រជាពលរដ្ឋមិនយល់អំពីរបៀបនៃការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។ លើសពីនេះទៀត ការគ្រប់គ្រងកន្លងមកធ្វើឡើងតែស្ថាប័នជំនាញប៉ុណ្ណោះ ឯប្រជាពលរដ្ឋដែលរស់នៅ និងប្រើប្រាស់ផ្ទាល់ពុំត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងដំណើរការគ្រប់គ្រងឡើយ។

ដូច្នេះ តើគួរមានការលើកទឹកចិត្តឱ្យប្រជាពលរដ្ឋមូលដ្ឋានបានចូលរួមគ្រប់គ្រងធនធានតំបន់ឆ្នេរ ជាមួយរដ្ឋាភិបាលដែរឬ យ៉ាងណា? ហើយតើពួកគាត់ចូលរួមដោយរបៀបណា ?

ការចូលរួមរបស់សហគមន៍មូលដ្ឋាន អ្នកពាក់ព័ន្ធ និងស្ថាប័ននានា និងការផ្តល់សិទ្ធិអំនាចដល់ប្រជាពលរដ្ឋ គឺជាគន្លឹះដ៏សំខាន់ដែលមិនអាចខ្វះបានក្នុងការគ្រប់គ្រងធនធានតំបន់ឆ្នេរ។

## ២. ដំណើរការគ្រប់គ្រងសហគមន៍នេសាទនៅឧទ្យានជាតិព្រះសីហនុ "រាម" និង នៅដែនជំរកសត្វព្រៃពាមក្រសោប

### ២.១.មូលហេតុដែលនាំឱ្យមានការបង្កើតសហគមន៍នៅតំបន់ទាំងពីរ:

គំរោងរាមនិងពាមក្រសោបគឺជាគំរោងការចូលរួមគ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍មុនគេបង្អស់នៅតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជាគឺកកើតឡើងនៅអំឡុងឆ្នាំ១៩៩៨ ។

ក្នុងកាលៈទេសៈដែលធនធានធម្មជាតិ កំពុងត្រូវរងនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ។ នៅរាមមានអង្គការ ETAP/UNDP បន្ទាប់មកគឺ និងបច្ចុប្បន្នគឺ DANIDA CZM ជាអ្នកឧបត្ថម្ភ ឯនៅពាមក្រសោបមាន គំរោង "ការចូលរួមគ្រងធនធានព្រៃកោងកាង (PMMR/IDRC)" ជាអ្នកឧបត្ថម្ភ។

មានកត្តាសំខាន់ៗមួយចំនួន(ដូចគ្នានិងខុសគ្នា) ដែលជំរុញឱ្យគំរោងទាំងពីរកកើតឡើង។